**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ: ០១៤ ស.ភ.ណ

ថ្ងៃអង្គារ ១២រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមពិគ្រោះថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ ទូទឹកកក និងទូទឹកចុច(ក្តៅ-ត្រជាក់)។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃព្រហស្បតិ៍ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទី ដល់១៦:៣០នាទី) ដល់ថ្ងៃអង្គារ ទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ត្រឹមវេលាម៉ោង ១៦:០០នាទី ក្នុងមួយច្បាប់តម្លៃ ១៦០,០០០រៀល។

កាលបរិច្ឆេទបង្ហាញទីតាំងដែលត្រូវតម្លើង ថ្ងៃអង្គារ ទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង០៩:០០នាទី។ ការដែលមិនបានចូលរួមពិនិត្យនូវទីតាំងដែលត្រូវតម្លើងគឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមពិគ្រោះថ្លៃផ្ទាល់។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើពិគ្រោះថ្លៃគឺ ថ្ងៃពុធ ទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ១៤:០០នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យពិគ្រោះថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការពិគ្រោះថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារពិគ្រោះថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធាន**

**ជួ ផល្លា**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ